# អុបាសកនិទ្ទេស

សំដែងអំពីនាមថា អុបាសក និងធម៌របស់អុបាសកផ្សេងៗ មានសីលជាដើម។ ជនដែលមាននាមបញ្ញាត្តិថា អុបាសក អុបាសិកា នោះដោយហេតុដែលបានចូល ទៅជិតនូវព្រះរតនត្រៃជាទីពឹងទីរលឹក ដូចពុទ្ធភាសិតដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សំដែងចំពោះ នឹងមហានាមសក្យរាជថា ម្នាលមហានាម គ្រហស្ថអែណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាទីពឹងទីរលឹកហើយ គ្រហស្ថនោះអែងបានឈ្មោះថា អុបាសក បើស្ត្រីហៅថា អុបាសិកា។

ម្យ៉ាងទៀតមានបាលីថា រតនត្តយំ អុបាសតីតិ អុបាសកោ ប្រែថា ជនអែណាចូល ទៅអង្គុយជិតព្រះរតនត្រៃ ជននោះឈ្មោះថា អុបាសក។

អធិប្បាយថា ជនដែលចូលទៅអង្គុយជិតព្រះរតនត្រៃនោះ គឺមិនមែនចូលទៅអង្គុយជិតព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជានិច្ចដោយរូបកាយនោះទេ គឺលោកសង្គ្រោះយកនាមកាយជាប្រមាណ សូម្បីអ្នកនោះស្ថិតនៅក្នុងទីឆ្ងាយប៉ុន្មាន តែមានសន្តានចិត្ត ប្រព្រឹត្តចាប់នៅក្នុងគុណព្រះរតនត្រៃជានិច្ច ចិត្តនោះអោនទៅតោងយកគុណព្រះរតនត្រៃជាទីពឹងទីរលឹកហើយជននោះឈ្មោះថា បានចូលទៅអង្គុយជិតព្រះរតនត្រៃជានិច្ច បើគ្រាន់តែចូលទៅអង្គុយជិត ព្រះពុទ្ធដោយរូបកាយ តែសន្តានចិត្តនោះស្ថិតនៅក្នុងទីឆ្ងាយអំពីគុណព្រះរតនត្រៃ មិនមានបង្អោនចិត្តទៅក្នុងគុណព្រះរតនត្រៃ ឡើយ ជនឈ្មោះថា ស្ថិតនៅក្នុងទីឆ្ងាយអំពីគុណព្រះរតនត្រៃ មិនមែនជា អុបាសក អុបាសិកាឡើយ។

## សីលនៃអុបាសក

បញ្ចវិរតិចេតនា គឺវៀរចាកវេរា៥ ឈ្មោះថាជាសីលនៃអុបាសក ដូចពុទ្ធភាសិតដែលព្រះបរមគ្រូជាម្ចាស់ទ្រង់ត្រាស់សំដែងចំពោះមហានាមសក្យរាជថា ម្នាលមហានាម អុបាសកអែណាបានវៀរចាកបាណាតិបាត គឺមិនសំលាប់សត្វ១ វៀរចាកអទិន្នាទាន គឺមិនលួចទ្រព្យអ្នកដ៏ទៃ១ វៀរចាកកាមេសុមិច្ឆាចារ គឺមិនប្រ

ព្រឹត្តខុសក្នុងកាមទាំងឡាយ១ វៀរចាកមុសាវាទ គឺមិននិយាយកុហក១ វៀរចាកសុរាមេរយគឺមិន ផឹកនូវសុរា និងមេរ័យ១ អុបាសកនោះឈ្មោះថា អុបាសកមានសីល។

## អាជីវៈនអុបាសក

កិរិយាលះបង់នូវជំនួញខុស ៥ប្រការ ហើយប្រកបកិច្ចការចញ្ចឹមជីវិតដោយត្រឹមត្រូវ តាមធម៌ ឈ្មោះថា អាជីវៈនៃអុបាសក ដូចមានពុទ្ធបញ្ញាត្តិដែលព្រះសម្មាសម្ពុទ្ធទ្រង់ហាមចំពោះនឹងភិក្ខុទាំងឡាយ ជំនួញខុសទាំងឡាយ៥ប្រការនោះគឺ

១ -សត្ថវណិជ្ជា ជួញសស្ត្រាវុធសំរាប់ប្រហារ គឺធ្វើគ្រឿងសស្ត្រាវុធនោះដោយខ្លួនអែង រឺអោយអ្នកដទៃគេធ្វើអោយ រឺបានមកដោយហេតុអែណាមួយហើយលក់ដូរគ្រឿងសស្ត្រាវុធនោះ។

២ -សត្តវណិជ្ជា ជួញដូរមនុស្ស។

៣ -មំសវណិជ្ជា ជួញសាច់គឺចិញ្ចឹមនូវសត្វទាំងឡាយមានជ្រូកជាដើមលុះដល់សត្វទាំងឡាយនោះ ចំរើនធំឡើងក៏សំលាប់យកសាច់លក់។

៤ -មជ្ជវិណិជ្ជា ជួញទឹកស្រវឹង គឺផ្សំគ្រឿងណាមួយ អោយកើតឡើងជាទឹកស្រវឹងដោយខ្លួនអែង រឺទិញគេយកមក ហើយលក់ដូរទឹកស្រវឹងនោះ។

៥ -វិសវណិជ្ជា ជួញថ្នាំពិសគឺចាត់ចែងផ្សំថ្នាំពិសអោយកើតឡើងដោយខ្លួនអែង រឺអោយគេផ្សំអោយ រឺបានមកដោយហេតុអែណាមួយហើយលក់នូវថ្នាំពិសនោះ។

អុបាសក កាលបើវៀរចាកជំនួញខុសទាំង៥ប្រការនេះ ហើយបានប្រតិបត្តិការចិញ្ចឹមជីវិតដោយធម៌ ឈ្មោះថា មានអាជីវធម៌ដោយប្រពៃ។

## វិបត្តិនៃអុបាសក

ធម្មជាតិដែលញុាំងសីលនិងអាជីវធម៌នៃអុបាសកអោយវិនាសឈ្មោះថាវិបត្តិ វិបត្តិ នោះមាន៥យ៉ាងគឺះ

១ - អស្សទ្ធោ ហោតិ អុបាសកមិនជឿគុណព្រះរតនត្រៃ។

២ - ទុស្សីលោ ហោតិ អុបាសកទ្រុស្តសីល។

៣ - កោតុហលមង្គលិកោ ហោតិ អុបាសកប្រកបដោយមង្គលភ្ញាក់ផ្អើល។

៤ - មង្គលំ បច្ចេតិ នោ កម្មំ អុបាសកប្រកាន់ជឿថា មង្គលមានរិទ្ធពារវេលាជាដើមអោយផល មិនប្រកាន់ជឿថាកម្មជាកុសលអកុសលអោយផលឡើយ។

៥ - អិតោ ច ពហិទ្ធា ទក្ខិណេយ្យំ គវេសតិ តត្ថ ចបុព្វការំ ករោតិ អុបាសការស្វែងរកតែទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈអ្នកទទួលទានខាងក្រៅ ព្រះពុទ្ធសាសនា ហើយធ្វើនូវទានដល់ទក្ខិណេយ្យ បុគ្គលខាងក្រៅព្រះពុទ្ធសាសនានោះ។

អុបាសកអែណាប្រកបដោយវិបត្តិ៥យ៉ាងនេះ ត្រង់វិបត្តិអែណាមួយ អុបាសកនោះ ឈ្មោះថា អុបាសកចណ្ឌាល គឺអុបាសកដូចជាមនុស្សចណ្ឌាល ឈ្មោះថា អុបាសក មល គឺអុបាសកមានធម៌មន្ទិលសៅហ្មងផង ឈ្មោះថា អុបាសកបដិកិដ្ឋៈ គឺអុបាសកដែលអ្នកប្រាជ្ញទាំងឡាយលោកតិះដៀលផង។

## សម្បត្តិនៃអុបាសក

ធម្មជាតិដែលញ៉ាំងសីលនិងអាជីវធម៌ នៃអុបាសកអោយបរិបូណ៌អោយបរិសុទ្ធប្រពៃ ឈ្មោះថាសម្បត្តិ សម្បត្តិនោះមានប្រាំយ៉ាងគឺ

| | |
|---|---|
| ១ - សទ្ធោ ហោតិ | អុបាសកមានសេចក្តីជឿជាក់ច្បាស់ក្នុងគុណព្រះរតនត្រៃ។ |
| ២ - សីលវា ហោតិ | អុបាសកមានសីល។ |
| ៣ - នកោតុហលមង្គលិ | កោហោតិ អុបាសកប្រកបដោយសុភមង្គលមិនភ្ញាក់ផ្អើល។ |
| ៤ - កម្មំ បច្ចេតិ នោ | មង្គំ អុបាសកប្រកាន់ជឿថា កម្មជាកុសល និងកម្មជាអកុសលអោយផល មិនប្រកាន់ជឿមង្គលមានរិទ្ធពារវេលាជាដើមអោយផលឡើយ។ |
| ៥ - ន អិតោ ពហិទ្ធាទក្ខិ | ណេយ្យំ គវេសតិ អិធ ចបុព្វការំ ករោតិ អុបាសកមិនស្វែងរកទក្ខិណេយ្យបុគ្គល គឺបដិគ្គាហកៈអ្នកទទួលទានខាងក្រៅព្រះពុទ្ធសាសនាឡើយ ហើយធ្វើទានតែក្នុងទក្ខិណេយ្យបុគ្គលក្នុងព្រះ |

ពុទ្ធសាសនានេះ។

អុបាសកអែណាប្រកបដោយសម្បត្តិ ៥យ៉ាងនេះហើយ អុបាសកនោះឈ្មោះថា អុបាសករតនៈ គឺអុបាសក ដូចជារតនវត្ថុមានកែវជាដើមផង ឈ្មោះថាអបាសកបទុមៈ គឺជាអុបាសកដូចជាផ្កាឈូកមានពណ៌សផង។

## គុណនៃអុបាសក

ធម៌សំរាប់អុបាសកអុបាសិកាប្រតិបត្តិគ្រប់រូប ដើម្បីនឹងអោយកើត អោយចំរើននូវសម្បត្តិទាំងពួងឈ្មោះ ថាគុណ គុណនេះជារបស់អុបាសកអុបាសិកាហៅថា អុបាសកគុណ មាន១០យ៉ាងគឺះ

១ - សង្ឃេន សទ្ធឹ សមានសុខទុក្ខោ ហោតិ អុបាសកអ្នករួមសេចក្ដីសុខ ទុក្ខមួយ អន្លើដោយភិក្ខុសង្ឃ គឺ ថា បើភិក្ខុសង្ឃមានសេចក្ដីសុខក៏ត្រេកអរ បើភិក្ខុ សង្ឃមានសេចក្ដីទុក្ខព្រួយក៏ព្រួយជាមួយផង។

២ - កាយិកវចសិកញ្ច សុរក្ខិតំ ហោតិ អុបាសកមានធម៌ជាអធិបតី គឺថា កាលបើប្រព្រឹត្តធ្វើអ្វីៗ រមែងកា ន់យកធម៌ជាធំ ជាទីតាំង ជាទីអាងមាំ មិនអោយ ខុសមិនអោយឃ្លៀងឃ្លាតអំពីធម៌ឡើយ។

៣ - ធម្មោ អធិបតេយ្យោ ហោតិ អុបាសកមានធម៌ជាអធិបតី គឺថាកាល បើប្រព្រឹត្តធ្វើអ្វីៗ រមែងកាន់ យកធម៌ជាធំ ជាទីតាំងជាទីអាងមាំ មិនអោយខុសមិន អោយឃ្លៀងឃ្លាតអំពីធម៌ឡើយ។

៤ - យថា ថាមេន សំវិភាគរតោ វ ហោតិ អុបាសកជាអ្នកត្រេកអរក្នុង ការបរិច្ចាគទានតាមសមគួរដល់ កម្លាំងនៃខ្លួន គឺធ្វើទានតាមសមគួរដល់ទ្រព្យតិច និងច្រើន បើមានតិចក៏ធ្វើតិច បើមានច្រើនធ្វើ ច្រើនមិនមានមច្ឆរិយធម៌គ្របសង្កត់ សន្ដានចិត្តឡើយ។

៥ - ជិនសាសនំ ជានិតុញ្ច វាយមតិ អុបាសកអុស្សាហ៍ព្យាយាមដើម្បី នឹងអោយដឹងច្បាស់នូវសាសនៈ គឺពា ក្យប្រៀនប្រដៅពាក្យបណ្ដាំនៃព្រះជិនស្រី។

៦ - សម្មាទិដ្ឋិកោ វ ហោតិ អុបាសកជាសម្មាទិដ្ឋិ គឺមានប្រាជ្ញាឃើញត្រូវ តាមសេចក្ដីពិត។

៧ - អបគតោ កោតុហលមង្គលិកោវ ហោតិ អុបាសកប្រាសចាកមង្គល ភ្ញាក់ផ្អើលហើយជាអ្នកមិនប្រ កាន់ជឿថា មង្គលមានរិទ្ធពារវេលាជាដើមអោយផលឡើយប្រកាន់ជឿតែកម្មជាកុសល និងអកុស លថាអោយផល។

៨ - ជីវិតហេតុបិ អញ្ញំ សត្ថារំ ន អុទ្ទិសតិ អុបាសក បើទុកជាមានហេតុគួរដល់នូវសេចក្ដីវិនាសជីវិតក្ដី ក៏មិ នលះបង់ព្រះរតនត្រៃ ហើយត្រឡប់ទៅកាន់យកមនុស្សដទៃជាគ្រូអាចារ្យជាទីពឹងរបស់ខ្លួនថា ប្រ

សើរជាងព្រះរតនត្រៃឡើយ។

៩ - សមគ្គារាមោ វ ហោតិ អុបាសកមានសេចក្តីត្រេកអរក្នុងសាមគ្គីធម៌ គឺសេចក្តីព្រមព្រៀងគ្នា។

១០ - សាសនេ ចរតិ អុបាសកប្រព្រឹត្តិល្អក្នុងព្រះពុទ្ធសាសនា គឺប្រព្រឹត្តតាមតែធម៌ វិន័យជាពុទ្ធសាសនា។

អុបាសកៈគុណ ១០យ៉ាងនេះ អុបាសកអុបាសិកាគប្បីប្រព្រឹត្តតាមកុំអោយឃ្លៀងឃ្លាតឡើយ ព្រោះជាធម៌អាចនឹងធ្វើចិត្តអុបាសក អុបាសិកាអ្នកប្រព្រឹត្តប្រតិបត្តិអោយសុចរិតផ្សរផង់ក្នុងព្រះពុទ្ធសាសនាហើយអោយបានជាបច្ច័យនៃនិព្វាន សម្បត្តិផង។

ចប់អុបាសកនិទ្ទេសដោយសង្ខេបប៉ុណ្ណោះ។